ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ...០១៤........ន.គ.ស .ណលរន

ថ្ងៃ...... ខែ...... ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១

# សេចក្ដីណែនាំ

## ស្ដីពី

## នីតិវិធី និងបែបបទក្នុងការដាក់ពាក្យស្នើសុំក្លាយខ្លួនជាគណនេយ្យករជំនាញកម្ពុជា តាមគោលការណ៍ពិសេសតាមប្រព័ន្ធអនឡាញ

**និយ័តករគណនេយ្យនិងសវនកម្ម** មានកិត្តិយសសូមជម្រាបជូនដល់សាធារណៈជនមេត្តាជ្រាបថា កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (**គ.ក.គ.ក.**) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ កន្លងទៅនេះ ស្របតាមប្រកាសលេខ ៣១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ស្ដីពីការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងបណ្ដុះបណ្ដាលនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្ម ដើម្បីបំពេញតម្រូវការទីផ្សារនៃសេវាវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ទាំងក្នុងក្របខណ្ឌក្នុងស្រុក។ ដូច្នេះ ក្នុងលក្ខខណ្ឌបច្ចុប្បន្ន និងដើម្បីបំពេញតម្រូវការទីផ្សារនៃសេវាវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនេះឱ្យបានឆាប់រហ័ស **គ.ក.គ.ក.** បានរៀបចំសេចក្ដីសម្រេចស្ដីពី "**ការដាក់ឱ្យអនុវត្តគោលការណ៍ពិសេសសម្រាប់កម្មវិធីគណនេយ្យករជំនាញកម្ពុជា**" និងទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១។ ដូច្នេះ បេក្ខជនជាជនជាតិខ្មែរដែលមានបំណងក្លាយខ្លួនជាគណនេយ្យករជំនាញកម្ពុជាអាចដាក់ពាក្យស្នើសុំ មកនិយ័តករគណនេយ្យនិងសវនកម្ម ដោយអនុវត្តទៅតាមនីតិវិធី និងបែបបទក្នុងការដាក់ពាក្យស្នើសុំក្លាយជាគណនេយ្យករជំនាញកម្ពុជា តាមប្រព័ន្ធអនឡាញដូចខាងក្រោម÷

### ជំហានទី១÷ ការបំពេញពាក្យស្នើសុំក្លាយខ្លួនជាគណនេយ្យករជំនាញកម្ពុជា

បេក្ខជន អាចដាក់ពាក្យស្នើសុំតាមរយៈតំណភ្ជាប់ ccpa.acar.gov.kh ឬចូលទៅកាន់គេហទំព័ររបស់ និយ័តករគណនេយ្យនិងសវនកម្ម www.acar.gov.kh រួចចុចលើម៉ឺនុយ CPA បន្ទាប់មកចុចលើពាក្យ "កម្មវិធីគណនេយ្យករជំនាញកម្ពុជា" រួចសូមធ្វើការបំពេញព័ត៌មាននៅក្នុង *ផ្នែកទី១÷ប្រវត្តិរូបសង្ខេប* *ផ្នែកទី២÷កម្រិតវប្បធម៌* និង*ផ្នែកទី៣÷បទពិសោធន៍ការងារ*។

បន្ទាប់មកបេក្ខជនត្រូវធ្វើការដាក់បញ្ជូនឯកសារភ្ជាប់នៅក្នុង*ផ្នែកទី៤÷ការដាក់បញ្ជូនឯកសារពាក់ព័ន្ធ*ដែលមានដូចជា÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ: ០២៣ ៨៨២ ១១១
Phone: 023 882 111

- បញ្ជីឈ្មោះសៀវភៅដែលបានបញ្ចប់តាមកម្មវិធីរបស់សមាគមគណនេយ្យករជំនាញជាន់ខ្ពស់ (ACCA)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង (ជាទម្រង់ PDF)
- ប្រវត្តិរូប (ជាទម្រង់ PDF)
- រូបថត ថតថ្មីទំហំ ៤ x ៦
- វិញ្ញាបនបត្រ ឬឯកសារបញ្ជាក់ពីការបញ្ចប់មុខវិជ្ជាដូចមានចែងក្នុងប្រការ៣ នៃសេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ពិសេសសម្រាប់កម្មវិធីគណនេយ្យករជំនាញកម្ពុជា (ជាទម្រង់ PDF)។

ចុងក្រោយនៅក្នុង *ផ្នែកទី៥÷ការបង់កម្រៃដាក់ពាក្យស្នើសុំ* បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់កម្រៃសម្រាប់ការដាក់ពាក្យស្នើសុំចំនួន ៤០,០០០ (សែសិបពាន់ ) រៀល។ ក្រោយពីបង់កម្រៃដាក់ពាក្យស្នើសុំនៅបញ្ជរធនាគារ ឬស្កេន QR-Pay ឬផ្ទេរតាមប្រព័ន្ធធនាគារទៅគណនីរបស់ និយ័តករគណនេយ្យនិងសវនកម្ម រួចបុគ្គលដាក់ពាក្យស្នើសុំត្រូវបញ្ចូលលេខប្រតិបត្តិការ (Transaction Reference Number/Reference Number) និងបញ្ចូលដាក់ភ្ជាប់បង្កាន់ដៃដាក់ ឬផ្ទេរប្រាក់ចូលក្នុងប្រព័ន្ធ។

គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា នឹងធ្វើការពិនិត្យវាយតម្លៃ និងជូនដំណឹងពីការអនុម័តយល់ព្រម ឬបដិសេធលើការស្នើសុំក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីទទួលបានការដាក់ពាក្យស្នើសុំនិងឯកសារភ្ជាប់ពេញលេញ តាមរយៈសារអេឡិចត្រូនិច (Email)។

**<u>ជំហ៊ានទី២÷ ការបង់កម្រៃលើកលែងការប្រឡងតាមកម្រិតមុខវិជ្ជា</u>**

បន្ទាប់ពីទទួលបានការអនុម័តយល់ព្រមលើពាក្យស្នើសុំ បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់កម្រៃលើកលែងការប្រឡងតាមកម្រិតមុខវិជ្ជា ដូចមានកំណត់ក្នុងប្រការ ៨ នៃសេចក្តីសម្រេចស្តីពី ការដាក់ឱ្យអនុវត្តគោលការណ៍ពិសេសសម្រាប់កម្មវិធីគណនេយ្យករជំនាញកម្ពុជាក្នុងរយៈពេល ៤៥ ថ្ងៃ។ ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញទៅតាមលក្ខខណ្ឌកំណត់ ការដាក់ពាក្យស្នើសុំត្រូវទុកជាមោឃៈ និងត្រូវធ្វើការដាក់ពាក្យស្នើសុំឡើងវិញ។

ក្រោយពីបង់កម្រៃលើកលែងការប្រឡងតាមកម្រិតមុខវិជ្ជានៅបញ្ជរធនាគារ ឬស្កេន QR-Pay ឬផ្ទេរតាមប្រព័ន្ធធនាគារទៅគណនីរបស់ និយ័តករគណនេយ្យនិងសវនកម្ម រួចបុគ្គលដាក់ពាក្យស្នើសុំត្រូវបញ្ចូលលេខប្រតិបត្តិការ និងបញ្ចូលបង្កាន់ដៃដាក់ ឬផ្ទេរប្រាក់ចូលក្នុងប្រព័ន្ធ តាមរយៈតំណភ្ជាប់ (Link) ដែលបានភ្ជាប់ជូនក្នុងសារអេឡិចត្រូនិច (Email)។

***<u>ឈ្មោះគណនី លេខគណនី និងQR-Pay (ជាប្រាក់រៀល) សម្រាប់ការបង់ប្រាក់</u>***

| ឈ្មោះគណនី | លេខគណនី | ធនាគារ | QR-Pay |
|---|---|---|---|
| និយ័តករគណនេយ្យនិងសវនកម្ម | 0001-04-200550-1-3 | អេស៊ីលីដា | |

**និយ័តករគណនេយ្យនិងសវនកម្ម**